ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 12 / 2012
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: [illegible]

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ព្រហស្បតិ៍ ទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី (សុខភាពរបស់ អៀង សារី) - ថ្ងៃទី ១២៩

រៀបចំដោយ: ឌុច ផារី និង Roger PHILLIPS

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធួ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Roger PHILLIPS, លោកស្រី សែ កុលវុឌ្ឍី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ច័ន្ទ តារាវស្សី, លោក William Smith |
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ) |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Andrew Ianuzzi |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក ពេជ អង្គ, លោក វ៉ែន ពៅ, លោក សំ សុគង់, លោកស្រី ជេត វណ្ណលី , លោកស្រី ស៊ិន សុវ៉ន, លោកស្រី Beini YE, លោកស្រី Christine MARTINEAU, លោកស្រី Pascal AUBOIN, លោកស្រី Nushin SAKARATI |
| សាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី/អ្នកជំនាញ៖ សាស្ត្រាចារ្យ John CAMPBELL (អ្នកជំនាញ) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី ស្វ សុទ្ធាវី |
| ផ្សេងៗ៖ លោក Simon MEISENBERG កញ្ញា Anne-Elise JOLICARD |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.១០ | បញ្ចប់ម៉ោង៖១៦.១០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.១០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលល្ងាច | ចាប់ផ្តើមម៉ោង៖១៤.២៥ | បញ្ចប់ម៉ោង៖ ១៤.៤៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៥ ម៉ោង | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | អង្គជំនុំជម្រះ | ៩.២៧ | ៩.២៨ |
| ការតាំងសំណួរដល់អ្នកជំនាញសាស្ត្រាចារ្យ A. John Campbell | អង្គជំនុំជម្រះ<br>មេធាវីការពារក្តី អៀង សារី<br>សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ៩.៣៤<br>១០.៥០<br>១៤.៤៥<br>១៥.៥១ | ១០.៣០<br>១៤.២៥<br>១៥.៥១<br>១៥.៥៦ |
| សេចក្តីសម្រេចអំពីស្ថានភាពរបស់លោក អៀង សារី | អង្គជំនុំជម្រះ | ១៦.០០ | ១៦.០៣ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**ការតាំងសំណួរដល់អ្នកជំនាញសាស្ត្រាចារ្យ A. John Campbell**

អង្គជំនុំជម្រះតាំងសំណួរដល់អ្នកជំនាញ A. John Campbell ទាក់ទងនឹងសុខភាពរបស់ជនជាប់ចោទ អៀង សារី។ បន្ទាប់មក ការសួរសំណួរបន្តដោយមេធាវីការពារក្តី អៀង សារី សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**សេចក្តីសម្រេចអំពីស្ថានភាពរបស់លោក អៀង សារី**

អង្គជំនុំជម្រះបានកត់សម្គាល់ថា វាជាការសមស្របដែលត្រូវធ្វើការកំណត់ជាបណ្តោះអាសន្នទាក់ទងនឹងកន្លែងស្នាក់នៅរបស់លោក អៀង សារី ក្នុងអំឡុងពេលដែលរង់ចាំនូវសេចក្តីសម្រេចអំពីស្ថានភាពសុខភាពរបស់លោក អៀង សារី នាពេលបច្ចុប្បន្ន ។ អង្គជំនុំជម្រះបានកត់សម្គាល់នូវការយល់ឃើញរបស់សាស្ត្រាចារ្យ John Campbell ដែលក្នុងនោះ លោកសាស្ត្រាចារ្យយល់ឃើញថាលោក អៀង សារី មិនតម្រូវឱ្យស្នាក់នៅក្នុងមន្ទីរពេទ្យទេនាពេលបច្ចុប្បន្ន ។

ហេតុដូច្នេះ អង្គជំនុំជម្រះបានសម្រេចថា លោក អៀង សារី ត្រូវបញ្ជូនទៅកាន់មន្ទីរឃុំឃាំងវិញ ដែលនៅទីនោះគាត់នឹងបន្តទទួលនូវការព្យាបាលវេជ្ជសាស្ត្រដូចពេលមុន និងដូចដែលបានពិភាក្សាក្នុងអំឡុងពេលសវនាការថ្ងៃនេះ ។ បន្ថែមលើនេះ អង្គជំនុំជម្រះបានណែនាំដល់មន្ទីរឃុំឃាំងឱ្យផ្តល់នូវការជួយផ្សេងៗទៀតដល់លោក អៀង សារី ដើម្បីធានានូវសុវត្ថិភាពរបស់គាត់ និងដើម្បីឱ្យគាត់អាចធ្វើការងារដោយខ្លួនឯង ដូចជាការប្រើប្រាស់បន្ទប់ទឹកជាដើម ។

ហេតុដូច្នេះ អង្គជំនុំជម្រះបានបង្គាប់ឱ្យនាំជនជាប់ចោទ អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ ។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា ជនជាប់ចោទ អៀង សារី បានលះបង់សិទ្ធិក្នុងការមានវត្តមានដោយផ្ទាល់ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សីមួយចំនួន ដែលត្រូវបានកោះហៅមកផ្តល់សក្ខីកម្មរហូតដល់ចប់ខែ វិច្ឆិកា ឆ្នាំ ២០១២ ។ ដូច្នេះ អង្គជំនុំជម្រះមិនតម្រូវឱ្យមានវត្តមានរបស់ជនជាប់ចោទនៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សីទាំងនោះ នោះទេ។ សេចក្តីសម្រេចទាក់ទងនឹងស្ថានភាពសុខភាពរបស់លោក អៀង សារី នឹងចេញក្នុងពេលសមស្រប ហើយអង្គជំនុំជម្រះនឹងចេញនូវការបង្គាប់បញ្ជាទាក់ទងនឹងវត្តមានរបស់លោក អៀង សារី នៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ។

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ ។ ជនជាប់ចោទ អៀង សារី មានអាការៈអស់កម្លាំងខ្លាំង វិលមុខ ឈឺចង្កេះ មើលមិនសូវច្បាស់ ហើយគាត់មិនអាចដើរ ឬឡើងជណ្តើរបាននោះទេ ។ ទោះជាយ៉ាងណា វេជ្ជបណ្ឌិតបានបញ្ជាក់ផងដែរថា គាត់មានសមត្ថភាពរាងកាយ និងសត្តិបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ។ វេជ្ជបណ្ឌិតក៏បានបញ្ជាក់ផងដែរថា លោក អៀង សារី អាចពិភាក្សាជាមួយមេធាវីរបស់គាត់ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការបាន ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី ចូលរួមដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការសម្រាប់ រយៈពេលពេញមួយថ្ងៃ ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in France |
|---|---|---|---|---|---|---|---|
| N/A | E222 | 00838758-00838759<br>00837723-00837723 | អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការពិនិត្យសុខភាពរបស់ជនជាប់ចោទ អៀង សារី<br>Trial Chamber memorandum entitled "Medical examination of accused IENG Sary" | S | | | |
| N/A | E222/1 | 00847222-00847243<br>00846186-00846202 | របាយការណ៍ពេទ្យរបស់អ្នកជំនាញទាក់ទងនឹងលោក អៀង សារី<br>Expert Medical Report on Mr. IENG Sary | S | | 00846914, 00846191 | |
| N/A | E238 | 00852376-00852377<br>00851177-00851177<br>00853092-00853093 | អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការតែងតាំងសាស្ត្រាចារ្យ A. John CAMPBELL សម្រាប់ជនជាប់ចោទ អៀង សារី<br>Trial Chamber memorandum entitled "Re-appointment of Professor A. John CAMPBELL (IENG Sary)"<br>Mémorandum de la Chambre de première instance intitulé "Nouvelle désignation en tant qu'expert du professeur A. John CAMPBELL (s'agissant de IENG Sary)" | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| N/A | E239 | 00855458-00855458<br>00855457-00855457 | ការកំណត់កាលបរិច្ឆេទនៃការស្ដាប់សក្ខីកម្មរបស់អ្នកជំនាញវេជ្ជសាស្ត្រ (សាស្ត្រាចារ្យ Campbell និង វេជ្ជបណ្ឌិត LOR Vann Thary)<br>Scheduling of Medical Expert testimony (Professor Campbell and Dr. LOR Vann Thary) | P | | | |
| N/A | E239/1.1 | 00858138-00858138<br>00858078-00858078 | អនុស្សរណៈស្ដីពី៖ ការដកខ្លួនវេជ្ជបណ្ឌិត ឡោ វណ្ណថារី ពីការកិច្ចដូចមានរៀបរាប់ក្នុងឯកសារ E238 និងឯកសារ E239<br>Memorandum entitled "Dr. LOR Vann Thary withdrawal from expertise as described in E238 and E239" | C | | | |
| N/A | E115.2.2 | 00741433-00741477<br>00740661-00740689 | ប្រវត្តិរូបការងាររបស់វេជ្ជបណ្ឌិតHarold J. Bursztajn<br>Curriculum Vitae of Harold J. Bursztajn, MD | C | | | |
| N/A | E11/87/2 | 00848124-00848127<br>00848142-00848144<br>00847922-00847923 | របាយការណ៍សុខភាពរបស់លោក អៀង សារី ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២<br>Medical report of IENG Sary on 19 September 2012<br>Rapport médical de IENG Sary du 19 septembre 2012 | S | | 00848142 | |
| N/A | E238/4 | 00858941-00858949<br>00858695-00858701 | របាយការណ៍អ្នកជំនាញស្ដីអំពី លោក អៀង សារី ដែលត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E238)<br>Expert report relating to Mr. IENG Sary prepared in response to Trial Chamber request (E238) | S | 00858949 | 00858700 | |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី ចូលរួមសវនាការពីបន្ទប់ឃុំខ្លួន នៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ (លិខិតលះបង់សិទ្ធិត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ) ។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនអ្នកជំនាញ John Campbell ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ វិញ ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ ។ អង្គ - ជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា ជនជាប់ចោទ អៀង សារី បានលះបង់សិទ្ធិក្នុងការមានវត្តមាន

ដោយផ្ទាល់ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សីមួយចំនួន ដែលត្រូវបានកោះហៅមកផ្តល់សក្ខីកម្មរហូតដល់ចប់ខែ វិច្ឆិកា ឆ្នាំ ២០១២ ។

| **<u>កាលបរិច្ឆេទបន្តសវនាការ៖</u>** |
|---|
| សវនាការនឹងបន្តនៅថ្ងៃ ច័ន្ទ ទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០៨ វិច្ឆិកា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឌុច ផារី Roger PHILLIPS